# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាននៃកងយោធពលខេមរភូមិន្ទទាំងអស់ ក្រោយពីបានតាមដានយ៉ាងយកចិត្តទុកដាក់ អំពីព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ជាអាយុជីវិតជាតិ ពាក់ព័ន្ធនឹងការបញ្ជាក់អំពីភាពច្បាស់លាស់ត្រឹមត្រូវនិងភាពស្របច្បាប់នៃផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់ព្រំដែនរដ្ឋជាមួយប្រទេសជិតខាង។

យើងខ្ញុំទាំងអស់គ្នា សូមគាំទ្រទាំងស្រុងនិងយ៉ាងពេញទំហឹង ចំពោះសេចក្តីថ្លែងការណ៍ពិសេសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការបំភ្លឺជូនដល់ជនរួមជាតិកម្ពុជា អំពីផែនទីព្រំដែនរដ្ឋ រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ដែលបានផ្សព្វផ្សាយជាសាធារណៈ នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ ដែលជាសារនយោបាយប្រកបដោយអត្ថន័យជ្រាលជ្រៅ ក្នុងភាពជាអ្នកដឹកនាំដែលមានការទទួលខុសត្រូវខ្ពស់របស់ **សម្តេចតេជោ** ដែលបានបញ្ជាក់ពីសច្ចភាព និងភាពម៉ឺងម៉ាត់ ហ្មត់ចត់ ត្រឹមត្រូវ ភាពស្របច្បាប់ និងការទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្ររបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងមានចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចតេជោ** នៅក្នុងកិច្ចការដ៏មានសារៈសំខាន់ជាអាយុជីវិតជាតិមាតុភូមិកម្ពុជា ក្នុងការកំណត់ និងបោះបង្គោលព្រំដែនរដ្ឋ ជាមួយសាធារណៈរដ្ឋសង្គមនិយមវៀតណាម ដើម្បីបញ្ចៀសនិងបញ្ចប់ការភាន់ច្រឡំពីសាធារណមតិ ដែលអាចបង្កឲ្យមានការបែកបាក់ឯកភាពជាតិ សន្តិភាព និងមិត្តភាព ជាមួយប្រទេសជិតខាង។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា សូមប្រកាសគាំទ្រយ៉ាងឧឡារិកចំពោះរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិតខ្ពង់ខ្ពស់របស់ **សម្តេចតេជោ** នាយករដ្ឋមន្ត្រី និងសូមគាំទ្រចំពោះវិធានការបន្តដែល **សម្តេច** បានដាក់ចេញកាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ ក្នុងការបន្តចរចាកំណត់និងបោះបង្គោលព្រំដែនរដ្ឋជាមួយប្រទេសជិតខាង សំដៅធានាសុខសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការណ៍និងអភិវឌ្ឍន៍ជាមួយប្រទេសជិតខាង ព្រមទាំងធានាឲ្យបាននូវបូរណភាពទឹកដីមិនឲ្យបាត់បង់សូម្បីតែមួយម៉ែត្រក្រឡា។ ទន្ទឹមនិងនេះយើងខ្ញុំទាំងអស់គ្នាសូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្កាចំពោះទង្វើរបស់ជនមួយចំនួន ដែលតែងតែបានធ្វើការប្រឌិតនិងចោទប្រកាន់មូលបង្កាច់ទាំងងិតងងល់ មកលើកិច្ចខិតខំប្រឹង-ប្រែងយ៉ាងស្មោះសរ និងដើម្បីឧត្តមប្រយោជន៍ជាតិរបស់រាជរដ្ឋាភិបាល លើការងារព្រំដែននេះ។ សូមអំពាវនាវឲ្យមានការចាត់វិធានការផ្លូវច្បាប់ឲ្យបានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនីតិរដ្ឋក្នុងគោលបំណងថែរក្សា សន្តិភាព ស្ថិរភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ របស់សង្គមជាតិ។

យើងខ្ញុំសូមប្តេជ្ញាចិត្តយ៉ាងមោះមុតក្លៀវក្លា បន្តប្រណិប័តន៍តាមមាគ៌ាដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងបុព្វហេតុការពារបូរណភាពទឹកដី សន្តិភាព ការអភិវឌ្ឍន៍ជាតិ និងភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh